**អភិរក្ស និងអភិវឌ្ឍន៍អក្សរសាស្ត្រជាតិខេមរា**

# បុណ្យវិសាខបូជា

**កៀង ជីម**
ប្រធានផ្នែកអក្សរសិល្ប៍ពុទ្ធនិយម
សមាគមអ្នកអក្សរសិល្ប៍កម្ពុជា- សអក




ថ្ងៃទី១៥កើត ខែពិសាខ ជារៀងរាល់ឆ្នាំគឺជាទិវាដែលពុទ្ធសាសនិកជននៅទូទាំងសកលលោកតែងនាំគ្នាប្រារព្ធពិធីបុណ្យដ៏សំខាន់មួយគឺ **វិសាខបូជា** នេះឡើង។

តើពិធីបុណ្យវិសាខបូជាមានអត្ថប្រយោជន៍យ៉ាងណាសម្រាប់មនុស្សជាតិទូទៅ ទើបអង្គការសហប្រជាជាតិទទួលស្គាល់ជាទិវាបុណ្យរបស់ខ្លួន?

វិសាខបូជា ឬ ពិសាខបូជា គឺជាពិធីបុណ្យដែលពុទ្ធសាសនិកចាត់ទុកថា មានសារៈសំខាន់បំផុតមួយក្នុងចំណោមបុណ្យដទៃទៀតនៃព្រះពុទ្ធសាសនា ។ ពីព្រោះជាការគោរព រំឭកនឹកដល់ព្រឹត្តិការណ៍ធំៗបីនាសម័យកាលរបស់ព្រះសម្មាសម្ពុទ្ធសមណគោតមបរមគ្រូនៃលោក គឺ÷

១ - ថ្ងៃដែលព្រះអង្គទ្រង់ប្រសូតិ,

២ - ថ្ងៃដែលព្រះអង្គបានត្រាស់ដឹង,

៣ - ដាក់អាយុសង្ខារចូលបរិនិព្វាន។

ព្រះពុទ្ធ មានព្រះនាមដើមថា **សិទ្ធត្ថ** (អានថា សិត -ធ័ត) ដែលជាព្រះរាជបុត្រារបស់ព្រះនាង **សិរិមហាមាយា** និង ព្រះបាទ **សុទ្ធោធនៈ**។ ព្រះអង្គ ត្រូវបានគេហៅព្រះនាមជាច្រើនទៀត ដូចជា÷ **ព្រះសម្មាសម្ពុទ្ធ, ព្រះសមណគោតម, ព្រះជិនស្រី, ព្រះសក្យមុនី, ព្រះបរមគ្រូ, ព្រះសាស្តា** ជាដើម។ ព្រះអង្គទ្រង់ប្រសូតិ នៅថ្ងៃសុក្រ ពេញបូណ៌មី ខែវិសាខ មុនគ្រិស្តសករាជចំនួន ៥៤៣ឆ្នាំ។ នៅពេលមានព្រះជន្ម ២៩ឆ្នាំ **ព្រះសិទ្ធត្ថ** បានយាងទៅសាងផ្នួស។ ក្រោយពីក្លាយខ្លួនជាអ្នកបួសអស់រយៈពេល ០៦ឆ្នាំ ព្រះអង្គក៏បានត្រាស់ដឹងជាព្រះពុទ្ធ នៅថ្ងៃពុធ ពេញបូណ៌មី ខែវិសាខ នាវេលាទៀបភ្លឺ ។

ព្រឹត្តិការណ៍ទាំងបីនេះគឺកើតឡើងនៅចំថ្ងៃ ១៥កើត ពេញបូណ៌មី ដែលមានព្រះចន្ទពេញវង់ ក្នុងខែពិសាខ ដូចគ្នា ខុសតែឆ្នាំប៉ុណ្ណោះ។

អំពីចំណុចសំខាន់នៃបុណ្យវិសាខបូជាគឺជាទិវាប្រវត្តិសាស្ត្រមួយ របស់ព្រះពុទ្ធសាសនាដែលមានអាយុកាល ២៥៦៤ឆ្នាំមកហើយ ដោយផ្សារភ្ជាប់ទៅនឹងប្រភពដើមនៃពុទ្ធសករាជ ដែលប្រទេសកាន់ពុទ្ធសាសនាបាននិយមប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ ÷ "**ជាអាយុរបស់ព្រះពុទ្ធសាសនា ពីព្រោះពុទ្ធសាសនាយើងរាប់ជាសករាជឡើង នៅថ្ងៃបន្ទាប់ពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធបានចូលបរិនិព្វាន។ ដូច្នេះគ្រប់ប្រទេសទាំងអស់ ដែលកាន់ព្រះពុទ្ធសាសនានៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះក្តី នៅក្នុងពិភពលោកទាំងមូលក្តី តែងតែប្រារព្ធធ្វើទិវាវិសាខបូជា ហើយដែលពុទ្ធសាសនិកជនទាំងអស់បានប្រារព្ធពិធីនេះជាយូរមកហើយ...**"។

នេះជាបុព្វហេតុដែលនាំឱ្យពុទ្ធសាសនិកទូទាំងសកលលោក ជារៀងរាល់ឆ្នាំ ទោះបីជាពិធីបុណ្យឆ្នាំថ្មីប្រពៃណីខ្មែរឈានចូលមកដល់នៅក្នុងខែចេត្រក្តី ប៉ុន្តែរហូតដល់ថ្ងៃ ១រោច ខែវិសាខ

គឺ ១ថ្ងៃក្រោយពិធីបុណ្យវិសាខបូជាទើបបដិទិនច័ន្ទគតិខ្មែរ ដែលគិតតាមដំណើរគោចរនៃព្រះច័ន្ទ ផ្លាស់ចូលពុទ្ធសករាជថ្មី។ ដូចជាក្នុងឆ្នាំនេះ ថ្ងៃសង្ក្រាន្តឆ្នាំថ្មី ឆ្នាំជូត ទោស័ក ត្រូវប៉ះចំថ្ងៃច័ន្ទ ០៦-រោច ខែចេត្រ ប៉ុន្តែគឺនៅក្នុងពុទ្ធសករាជ២៥៦៣ដដែល រហូតដល់ថ្ងៃពុធ ១៥កើត ខែវិសាខ ដែលជាថ្ងៃបុណ្យវិសាខបូជា ត្រូវនឹងថ្ងៃ ទី០៦ ខែឧសភា ឆ្នាំ២០២០។ ពិធីបុណ្យអន្តរជាតិដ៏សំខាន់នេះរួចហើយ ទើបពុទ្ធសករាជ ២៥៦៤ ឈានចូលមកដល់ដោយបរិបូណ៌ នៅថ្ងៃ ១រោច ខែពិសាខ។

ទាក់ទងនឹងប្រវត្តិដើមកំណើតនៃពិធីបុណ្យវិសាខបូជានេះ សៀវភៅ "**ព្រះរាជពិធីទ្វាទសមាស**" បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ក្នុងគ្រិស្តសករាជ ១៩៥១ បានសរសេរកត់ត្រាថា÷ "ទោះបីជាពិធីបុណ្យវិសាខបូជា ត្រូវបានពុទ្ធបរិស័ទនាំគ្នាប្រារព្ធធ្វើជាទំនៀមទម្លាប់តាំងពីបូរាណយូរអង្វែងមកហើយក្តី អ្នកសិក្សាស្រាវជ្រាវផ្នែកពុទ្ធសាសនាខ្លះ បានបញ្ជាក់ថា ពុំមានឯកសារណាមួយកត់ត្រាអំពីកាលបរិច្ឆេទ ឬថ្ងៃ ខែ ឆ្នាំ នៃការចាប់ផ្តើមប្រារព្ធពិធីបុណ្យដ៏សំខាន់បំផុតមួយនេះ ឱ្យបានច្បាស់លាស់ឡើយ។

ប៉ុន្តែក្នុងរយៈពេល ២១ឆ្នាំចុងក្រោយនេះ អង្គការសហប្រជាជាតិបានប្រកាសទទួលស្គាល់បុណ្យវិសាខបូជា ជាទិវាបុណ្យអន្តរជាតិ ដែលហៅថា "**យូអិន-វិសាខ (UN - Visak) ឬ វិសាខបូជានៃអង្គការសហប្រជាជាតិ**" ដោយមានការស្នើសុំពីប្រទេសនានានៅលើសកលលោក ដែលគោរពព្រះពុទ្ធសាសនា ក្នុងនោះរួមទាំងកម្ពុជា ផងដែរ នាសម័យប្រជុំក្រុមប្រឹក្សាពុទ្ធសាសនាអន្តរជាតិ ក្នុងប្រទេសស៊ីរីលង្កា នាខែវិច្ឆិកា ឆ្នាំ១៩៩៨។

ចំពោះហេតុផលចម្បងមួយដែលញុំាងឱ្យមានការទទួលស្គាល់នេះ បានបញ្ជាក់ថា គឺអាស្រ័យដោយគោលការណ៍សន្តិភាពនិងអហិង្សាធម៌របស់ព្រះពុទ្ធសាសនា ដែលស្របនឹងគោលការណ៍គ្រឹះនៃអង្គការសហប្រជាជាតិ ដោយគេសង្កេតឃើញថា÷ ព្រះពុទ្ធសាសនាគឺបានឱ្យតម្លៃទៅលើនិន្នាការខាងសន្តិភាពនិយម។ ពាក្យដែលថា ធម្មភាវៈ ឬនីតិភាវៈនេះ គឺសំដៅដល់ច្បាប់ធម្មជាតិ ឬធម្មនុញ្ញរបស់ពិភពលោក គឺកម្រងនីតិក្រម ឬប្រព័ន្ធច្បាប់ប្រកបដោយសុក្រឹតភាពល្អផុតលេខ មានសុចរិតភាព ឬយុត្តិធម៌ ល្អផុតលេខ ព្រមទាំងមានតម្លាភាព អព្យាក្រឹតភាពល្អផុតលេខ។ ក្នុងនោះព្រះពុទ្ធសាសនាបានប្រកាសថា **ធម្មោ ហវេ រក្ខតិ ធម្មចារី** ច្បាប់តែងតែគាំពារថែរក្សាអ្នកគោរពច្បាប់តែម្យ៉ាង ហ្នឹងបើយើងនិយាយឱ្យន័យទូលាយទៅ ប៉ុន្តែបើតាមពាក្យដែលយើងធ្លាប់ប្រើ គឺធម៌រមែងថែរក្សាអ្នកប្រព្រឹត្តធម៌...។

ចាប់តាំងពីអង្គការសហប្រជាជាតិបានប្រកាសទទួលស្គាល់វិសាខបូជា ជាទិវាបុណ្យអន្តរជាតិក្នុងឆ្នាំ១៩៩៩មក ប្រទេសដែលគោរពព្រះពុទ្ធសាសនានៅលើសកលលោក បាននាំគ្នាប្រារព្ធធ្វើពិធីបុណ្យវិសាខបូជាជាសកល ដែលមានឈ្មោះថា "យូអ៊ិន-វិសាខ ឬវិសាខបូជា នៃអង្គការសហប្រជាជាតិ" ដោយមានកិច្ចប្រជុំរបស់ក្រុមប្រឹក្សាពុទ្ធសាសនាអន្តរជាតិប្រចាំឆ្នាំនៅរៀងរាល់វិសាខបូជាម្តងៗ។

កត្តាទាំងនេះបង្ហាញអំពីគោលដៅ និងតួនាទីដ៏សំខាន់នៃពុទ្ធសាសនា ក្នុងការដោះស្រាយវិបត្តិសង្គម ដែលអង្គការសហប្រជាជាតិ បានសម្រេចដាក់បញ្ចូលវិសាខបូជា ជាទិវាបុណ្យអន្តរជាតិ ជាការរំឭកដល់ការលះបង់ដ៏ខ្ពង់ខ្ពស់របស់ព្រះសម្មាសម្ពុទ្ធសមណគោតម ក្នុងការស្វែងរកមាគ៌ាដោះទុក្ខ និងផ្សព្វផ្សាយនូវមាគ៌ាដ៏ប្រសើរគ្មានពីរនេះដល់មនុស្សលោក ប្រកបដោយក្តីមេត្តា ករុណា ដ៏បរិសុទ្ធឥតព្រំដែន របស់ទស្សនៈអប់រំរបស់ព្រះពុទ្ធសាសនា។

យោងតាមប្រសាសន៍របស់អ្នកសិក្សាស្រាវជ្រាវ ផ្នែកពុទ្ធសាសនានៅលើសកលលោក បានបញ្ជាក់អំពីមូលហេតុធំជាគោល ដែលនាំឱ្យអង្គការសហប្រជាជាតិ យកបុណ្យវិសាខបូជាជាទិវាអន្តរជាតិ ÷ *"ព្រោះគេឃើញនូវគុណប្រយោជន៍របស់ព្រះពុទ្ធសាសនា ទី១-ជាសាសនាដែលមានចំណាស់យូរ ២៥៦៤ឆ្នាំទៅហើយ...។ ទី២-ជាសាសនាមានគោលការណ៍សន្តិភាព មិនកាប់សម្លាប់គ្នា គោរពសិទ្ធិគ្នាក្នុងការរស់នៅទៅវិញទៅមក, ទី៣-ពុំដែលមានសង្គ្រាមដែលកើតឡើងក្នុងនាមព្រះពុទ្ធសាសនានោះទេ ហើយមានប្រជាជនដល់ទៅជាង ៥០០លាននាក់នាបច្ចុប្បន្ននេះនៅលើពិភពលោកទាំងមូលបានកាន់ព្រះពុទ្ធសាសនា..."។* កត្តាទាំងអស់នេះហើយដែលអង្គការសហប្រជាជាតិបានលើកតម្លៃព្រះពុទ្ធសាសនាថា បានចូលរួមចំណែកដ៏ក្រាស់ក្រែលធំធេងណាស់ក្នុងរក្សាសន្តិភាពពិភពលោក និងការរួមរស់ជាមួយនឹងគ្នាប្រកបដោយសុខដុមនីយកម្មរវាងជនជាតិនិងជនជាតិ ព្រមទាំងសាសនានិងសាសនាដទៃនៅលើសកលលោក៕

ថ្ងៃអាទិត្យ ទី១២កើត ខែពិសាខ ឆ្នាំជូតទោស័ក ព.ស.២៥៦៣

***ភ្នំពេញ,*** ត្រូវនឹងថ្ងៃទី០៣ ខែឧសភា គ.ស ២០២០